*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

សំណុំរឿងទាមទារអំពីការលែងលះជាអាទិ៍ (ឆ្នាំ2018 (K) លេខទី.....)
ដើមចោទ B
ចុងចម្លើយ A

# ឯកសារចម្លើយ

ថ្ងៃទី31 ខែមីនា ឆ្នាំ2018

**សូមគោរពជូន**
លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

ជាន់ទី៣៩ អាគារ Vattanac Tower ផ្ទះលេខNo. 66 ផ្លូវព្រះមុនីវង្ស
សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ ភ្នំពេញ
◆◆ការិយាល័យច្បាប់ (កន្លែងបញ្ជូន)

មេធាវីតំណាងក្នុងបណ្ដឹងរបស់ចុងចម្លើយ E ត្រា

ទី១ ការឆ្លើយតបចំពោះសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ
១ ច្រានចោលសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ។
២ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

ទី២ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ និង ការឆ្លើយតបចំពោះមូលហេតុនៃការទាមទារ
១ ទទួលស្គាល់ការទាមទារ១។
២ មិនទទួលស្គាល់មូលហេតុនៃការទាមទារ២ ត្រង់កថាខណ្ឌទី១។

ដើម្បីធ្វើឲ្យទំនាក់ទំនងរវាងអ្នកនៅកន្លែងធ្វើការមានភាពល្អប្រសើរ ចុងចម្លើយធ្លាប់ផឹកស្រាដែរ ប៉ុន្តែ មិនបានចាយលើចំណាយឥតប្រយោជន៍ជាពិសេសណាទេ។

ទទួលស្គាល់នូវកថាខណ្ឌទី២ ដែលលើកឡើងថា ដើមចោទមិនបានធ្វើការងារ ហើយរស់នៅដោយប្រើប្រាស់ប្រាក់ចំណូលរបស់ចុងចម្លើយ ប៉ុន្តែ ក្រៅពីនេះ មិនទទួលស្គាល់ទេ។

ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ ចុងចម្លើយបានចាប់ផ្ដើមខិតខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំងដើម្បីអាហារកាតព្វកិច្ចសម្រាប់ដើមចោទ និង កូនស្រីច្បង។ ដោយសារតែដើមចោទជាស្ត្រីមេផ្ទះទៀត ដូច្នេះ ការងារផ្ទះស្ទើរតែទាំងអស់ ចុងចម្លើយបានពឹងផ្អែកលើដើមចោទ ប៉ុន្តែដោយសារតែសេចក្ដីស្រលាញ់ចំពោះដើមចោទ និង កូនស្រីច្បង នៅថ្ងៃឈប់សម្រាកជាអាទិ៍ ចុងចម្លើយបានលេងជាមួយកូនស្រីច្បងជាអាទិ៍ ហើយបានសហការគ្នាក្នុងការចិញ្ចឹមបីបាច់កូន។

បដិសេធចោលនូវកថាខណ្ឌទី៣។ នៅពេលដែលចុងចម្លើយស្រវឹង ដើមចោទបាននិយាយរអ៊ូរទាំ ដូច្នេះហើយ ចុងចម្លើយធ្លាប់បានរុញខ្លួនរបស់ដើមចោទ ប៉ុន្តែ មិនដែលធ្លាប់បាន វាយដំខ្លាំងៗ ឬ បង្ករឲ្យមានរបួសស្នាមអ្វីទេ។

បដិសេធចោលនូវកថាខណ្ឌទី៤។ ចុងចម្លើយបានធ្វើការសន្ទនាក្នុងលក្ខណៈជាឪពុកនឹងកូនជាមួយនឹងកូនស្រីច្បង ទម្រាំដល់ពេលដែលដើមចោទបាននាំកូនស្រីច្បងយកទៅ។

ទទួលស្គាល់នូវកថាខណ្ឌទី៥ ដែលនិយាយអំពីចំណុចដែលដើមចោទបាននាំកូនស្រីច្បងយកទៅ ប៉ុន្តែ មិនបានដឹងអំពី ការទទួលស្គាល់របស់ដើមចោទទេ។

មានវិវាទចំពោះកថាខណ្ឌទី៦ ។ មិនអាចនិយាយបានថា មានមូលហេតុនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ទេ។

៣ មានវិវាទអំពីមូលហេតុនៃការទាមទារ៣។

៤ មានវិវាទអំពីមូលហេតុនៃការទាមទារ៤។ ចុងចម្លើយបានគិតថា ចង់ឲ្យដើមចោទ និង កូនស្រីច្បងវិលត្រឡប់មកវិញ ហើយរួមរស់ជីវភាពជាមួយគ្នា។

៥ អាស្រ័យហេតុនេះ តុលាការគួរតែច្រានចោលនូវ ការទាមទារឲ្យលែងលះ សំណងជម្ងឺចិត្ត និង ការចាត់ចែងបន្ទាប់បន្សំ គ្រប់ចំណុចនៃពាក្យសុំរបស់ដើមចោទ។

## ប្រភេទនៃភស្តុតាង

| | | |
|---|---|---|
| ១ | ភស្តុតាងលេខ ក១ | លិខិតថ្លែងការណ៍ |

## ឯកសារភ្ជាប់

| | | | |
|---|---|---|---|
| ១ | ភស្តុតាងលេខ ក១ | ច្បាប់ចម្លងនៃឯកសារចម្លើយ | ១ច្បាប់ |
| ២ | ភស្តុតាងលេខ ក១ | ច្បាប់ចម្លងនៃភស្តុតាងលេខ ក១ | ១ច្បាប់ |
| ៣ | ភស្តុតាងលេខ ក១ | លិខិតប្រគល់សិទ្ធិធ្វើជាអ្នកតំណាងដោយអាណត្តិ | ១ច្បាប់ |